ក្រសួងកិច្ចការនារី

សេចក្ដីសង្ខេបសម្រាប់គោលនយោបាយ ៤



# វិស័យអប់រំ

## យេនឌ័រក្នុងវិស័យអប់រំ និងការបណ្ដុះបណ្ដាលវិជ្ជាជីវៈ

### ការប៉ាន់ប្រមាណអំពីយេនឌ័រនៅកម្ពុជា

២០១៤

រូបភាពគំរបមុខ

សិស្សពូកែជានារីទាំង៥រូប ដែលប្រឡងជាប់សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិឆ្នាំ២០១៤។ មានសិស្ស១១នាក់ទទួល បាននិទ្ទេស A ក្នុងនោះ មានសិស្សស្រីចំនួន៥នាក់៖

**អិត ស្រីពៅ (១៨ឆ្នាំ)** មកពីខេត្តកំពង់ចាម សព្វថ្ងៃនាងកំពុងសិក្សានៅសកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ។ ទៅថ្ងៃអនាគត នាងចង់ក្លាយជាវេជ្ជបណ្ឌិត ដើម្បីជួយព្យាបាលដល់សមាជិកគ្រួសាររបស់នាង និងប្រជាជនគ្រប់រូបផងដែរ ។

**សម្បត្តិ វិបុលរ័ត្ន (១៨ឆ្នាំ)** មកពីទីក្រុងភ្នំពេញ នឹងបន្តការសិក្សាផ្នែកស្ថាបត្យកម្មនៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ។ នាងដឹងថា ស្ត្រីមិនចាប់អារម្មណ៍លើមុខជំនាញនេះទេ ប៉ុន្តែស្ថាបត្យករ ជាក្តីសុបិនរបស់នាង ។

**ចាន់ កិត្យាភារ៉ា (១៧ឆ្នាំ)** មកពីខេត្តកំពង់ស្ពឺ ហើយនាងនឹងបន្តការសិក្សានៅសកលវិទ្យាល័យអាមេរិកកាំងភ្នំពេញ ផ្នែកសេដ្ឋកិច្ច ។ នាងចង់ក្លាយជាអ្នកវិភាគសេដ្ឋកិច្ច នាងអាចជួយអភិវឌ្ឍសេដ្ឋកិច្ចប្រទេសកម្ពុជាបាន ។

**អ៊ិត សុខផល្លុន (១៨ឆ្នាំ)** មកពីខេត្តសៀមរាប ហើយនាងនឹងបន្តការសិក្សាសកលវិទ្យាល័យអាមេរិចកាំងភ្នំពេញផ្នែកជំនួញ និងសេដ្ឋកិច្ច ។ នាងចង់ក្លាយជាអ្នកជំនួញ និងអ្នកវិភាគសេដ្ឋកិច្ច ព្រោះនាងស្រឡាញ់ការងារនេះ ហើយនៅពេលខាងមុខនេះ កម្ពុជានឹងចូលជាសមាជិកអាស៊ាន ដូចនេះ នាងអាចជួយអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជានៅពេលនោះបាន ។

**យ៉ាន សោភា (១៨ឆ្នាំ)** មកពីខេត្តព្រៃវែង សព្វថ្ងៃនាងកំពុងសិក្សានៅសកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ។ នាងចង់ក្លាយជាវេជ្ជបណ្ឌិត ព្រោះថា សុខភាពមានសារៈសំខាន់ណាស់សម្រាប់ប្រជាជនគ្រប់រូប ។

# ជំពូកទី ៤
# វិស័យអប់រំ

## សមភាពយេនឌ័រក្នុងវិស័យអប់រំនិងការបណ្តុះបណ្តាលវិជ្ជាជីវៈ

### បរិបទគោលនយោបាយ

ព្រះរាជាណាចក្រកម្ពុជាបានទទួលជោគជ័យក្នុងការបង្កើតច្បាប់ គោលនយោបាយ ផែនការ និងរចនាសម្ព័ន្ធស្ថាប័នថ្នាក់ជាតិដ៏រឹងមាំ សម្រាប់គាំទ្រដល់ការលើកកម្ពស់សមភាពយេនឌ័រក្នុងវិស័យអប់រំនិងបណ្តុះបណ្តាលបច្ចេទេសនិងវិជ្ជាជីវៈ ។

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ មាត្រា៦៨  និងច្បាប់ស្តីពីការអប់រំ ឆ្នាំ២០០៧ មាត្រា៣១ ទទួលស្គាល់ថា ការទទួលបានការអប់រំមូលដ្ឋាន រយៈពេលប្រាំបួនឆ្នាំ គឺជាសិទ្ធិរបស់កុមារា និងកុមារីគ្រប់ៗរូប។

កម្ពុជាគឺជាប្រទេសហត្ថលេខីនៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រី និងបានប្តេជ្ញាចិត្តក្នុងការលុបបំបាត់ការរើសអើងលើក្មេងស្រី និងស្ត្រី នៅក្នុងវិស័យអប់រំ ស្របតាមមាត្រា១០នៃអនុសញ្ញានេះ ។

ឆ្លើយតបនឹងផែនការអប់រំសម្រាប់ទាំងអស់គ្នា ក៏ដូចជាសមភាពយេនឌ័រក្នុងវិស័យអប់រំ ចាប់តាំងពីឆ្នាំ២០០៨មក ក្រសួងអប់រំយុវជននិងកីឡា ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងស្ថាប័នពាក់ព័ន្ធ សម្រេចបានលទ្ធផលល្អគួរឱ្យកត់សម្គាល់លើការបញ្ជ្រាបយេនឌ័រនៅក្នុងគោលនយោបាយ និងផែនការក្នុងវិស័យរបស់ខ្លួន ដូចជាផែនការយុទ្ធសាស្ត្រវិស័យអប់រំ(២០០៩-២០១៣) ផែនការគោលស្តីពីការអភិវឌ្ឍន៍កម្មវិធីសិក្សា(២០១០-២០១៤) ផែនការអភិវឌ្ឍគ្រូបង្រៀន(២០១០-២០១៤) ផែនការគោលសម្រាប់ការអភិវឌ្ឍន៍សមត្ថភាពក្នុងវិស័យអប់រំ(២០១១-២០១៥) ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ



▲ គ្រូបង្រៀនជាស្ត្រីមានចំនួនតិចតួចនៅក្នុងគ្រឹះស្ថានអប់រំផ្នែកបច្ចេកវិទ្យា

(២០១១-២០១៥) គោលនយោបាយស្តីពីធនធានមនុស្សក្នុងវិស័យអប់រំ (ឆ្នាំ២០១២) គោលនយោបាយស្តីពីសាលាកុមារមេត្រីសម្រាប់ការអប់រំមូលដ្ឋាន(ឆ្នាំ២០១២) គោលនយោបាយស្តីពីគ្រូបង្រៀន(ឆ្នាំ២០១៣) គោលនយោបាយជាតិស្តីពីការអភិវឌ្ឍន៍ យុវជនកម្ពុជា(ឆ្នាំ២០១១) ផែនការយុទ្ធសាស្ត្រវិស័យការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ(ឆ្នាំ២០០៩-២០១៣) និងយុទ្ធសាស្ត្រទីផ្សារសង្គម៖ យុទ្ធសាស្ត្រសមធម៌យេនឌ័រក្នុងការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ (ឆ្នាំ២០១៤-២០១៨) ។

ច្បាប់ គោលនយោបាយ និងផែនការទាំងនេះ កំពុងរួមចំណែកក្នុងការលើកកម្ពស់សមភាពយេនឌ័រក្នុងការអប់រំនិងបណ្តុះបណ្តាលតាមរយៈការធ្វើឱ្យប្រសើរឡើង នូវហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ឱកាសទទួលបានការអប់រំនិងបណ្តុះបណ្តាលប្រសើរជាងមុន ការកែប្រែឥរិយាបថសង្គមដែលរើសអើងលើស្ត្រី និងការផ្តល់បរិយាកាសអំណោយផលដល់ការចូលរួមរបស់ស្ត្រីនៅគ្រប់ផ្នែកនិងគ្រប់កម្រិត។

**ស្របពេលដែលប្រទេសកម្ពុជាចូលរួមក្នុងសេដ្ឋកិច្ចអាស៊ានក្នុងឆ្នាំ២០១៥ ក៏ដូចជាការកំណត់ក្នុងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ដំណាក់កាលទី៣** *ការអភិវឌ្ឍន៍ធនធានមនុស្ស ប្រកបដោយគុណភាព សមភាព និងគុណធម៌ គឺជាកត្តាគន្លឹះសម្រាប់ទ្រទ្រង់កំណើនសេដ្ឋកិច្ច និងភាពប្រកួតប្រជែងរបស់ប្រទេសទាំងក្នុងពេល បច្ចុប្បន្ននិងក្នុងពេលអនាគត ជាពិសេសក្នុងពេលដែលកម្ពុជាឈានចូលទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសអភិវឌ្ឍនៅឆ្នាំ២០៥០ តាមចក្ខុវិស័យរយៈពេលវែងរបស់រាជរដ្ឋាភិបាល ។ ក្នុងន័យនេះ ការអភិវឌ្ឍន៍ធនធានមនុស្ស ជាពិសេសយុវជនគឺសំដៅទៅលើការកសាងសមត្ថភាពខាងចំណេះដឹង ចំណេះធ្វើ សហគ្រិនភាព ជំនាញប្រកបដោយការច្នៃប្រឌិតនៅគ្រប់វិស័យ ជាពិសេសផ្នែកវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ព្រមទាំងសមត្ថភាពក្នុងការស្រាវជ្រាវនិងការអភិវឌ្ឍន៍ ទន្ទឹមនឹងការលើកស្ទួយគុណភាពខាងសុខភាព កាយសម្បទា សីលធម៌ ស្មារតីទទួលខុសត្រូវនិងមនសិការស្នេហាជាតិ និងវិជ្ជាជីវៈរួមជាមួយនឹងប្រព័ន្ធសុវត្ថិភាពសង្គមគត់មត់ ដោយគ្មាន ការរើសអើងផ្នែកយេនឌ័រ ។*

## របកគំហើញសំខាន់ៗ

### គម្លាតយេនឌ័រក្នុងការចុះឈ្មោះចូលរៀន

- កម្ពុជាទទួលបានសមភាពយេនឌ័រក្នុងការចុះឈ្មោះចូលរៀនរបស់សិស្សានុសិស្សនៅបឋមនិងមធ្យមសិក្សាក្នុងខណៈដែលសមាមាត្រសិស្សនៅឧត្តមសិក្សាបាននិងកំពុងមានការកើនឡើងជាបន្តបន្ទាប់ពី៣៣,៨ភាគរយក្នុងឆ្នាំ២០០៨ ដល់ ៣៧,៦ភាគរយក្នុងឆ្នាំ២០១១[1] ។

- សមភាពយេនឌ័រក្នុងវិស័យអប់រំកំពុងមានការរីកចម្រើន ប៉ុន្តែនៅមានគម្លាតយេនឌ័រនៅឡើយបើពិនិត្យទៅតាមតំបន់និងអាយុ។ ក្មេងស្រីនៅតាមតំបន់ជនបទជាពិសេសកុមារជនជាតិដើមភាគតិច ជាទូទៅជួបការលំបាកជាងក្មេងស្រីនៅតំបន់ទីក្រុងក្នុងការទទួលបានការអប់រំ លើកលែងតែនៅកម្រិតមធ្យមសិក្សាបឋមភូមិដែលអត្រាក្មេងប្រុសមានតែ២៧ភាគរយប៉ុណ្ណោះ ចំណែកឯក្មេងស្រីមាន៣៣ភាគរយ[2]។

- ថ្វីត្បិតតែការទទួលបានការអប់រំក្នុងចំណោមមនុស្សវ័យក្មេងមានភាពរីកចម្រើនក៏

[1] ក្រសួងអប់រំ យុវជន និងកីឡា ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ ឆ្នាំ (២០០៨, ២០០៩, ២០១០, ២០១១)
[2] ក្រសួងអប់រំ យុវជន និងកីឡា ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ ឆ្នាំ (២០១២)

ដោយ ក៏ប៉ុន្តែសម្រាប់ក្រុមមនុស្សវ័យចំណាស់ អក្ខរភាពនៅ មានគម្លាតនៅឡើយរវាងបុរសនិងស្ត្រី។ អត្រាអក្ខរកម្មរបស់ពួកគេនៅមានកម្រិតទាប ដែលនៅតែជាបញ្ហាប្រឈមចម្បងផ្នែកយេនឌ័រនិងការ អភិវឌ្ឍន៍។

- ទោះបីជាការចូលរៀននៅថ្នាក់មត្តេយ្យសិក្សាមានការកើនឡើងជាបន្តបន្ទាប់ក៏ដោយ ការចូលរៀននៅមតេយ្យសាលានៅមានកម្រិត ហើយក្មេងជាច្រើនចុះឈ្មោះចូលរៀនយឺត ។ ទោះជាយ៉ាងនេះក៏ដោយ ពុំមានវិសមភាពយេនឌ័រក្នុងការចុះឈ្មោះចូលរៀននៅកម្រិតនេះទេ។

## កំណើននៃការចុះឈ្មោះចូលរៀនរបស់ក្មេងលើសអាយុ និងការប្រែប្រួលនៃការបោះបង់ការសិក្សារបស់កុមារ

- ចាប់តាំងពីឆ្នាំ២០០៨មកការចុះឈ្មោះចូលរៀនរបស់ក្មេងលើសអាយុនៅកម្រិតបឋមសិក្សាមានការកើនឡើងគួរឱ្យកត់សម្គាល់ កត្តានេះ បានធ្វើឱ្យមានផលប៉ះពាល់ដល់ភាពឆ្លាតវៃក្នុងការសិក្សារបស់កុមារ ជាពិសេសកុមារី។
- ចាប់តាំងពីឆ្នាំ២០០៨[3]មក អត្រានៃការបោះបង់ការសិក្សារបស់កុមារទាំងពីរភេទនៅថេរ ប៉ុន្តែអត្រានេះមានការប្រែប្រួលជាលើកដំបូងនៅឆ្នាំ២០១២ក្នុងនោះការបោះបង់ការសិក្សារបស់ក្មេងស្រីនៅកម្រិតបឋមសិក្សាមានអត្រាច្រើនជាងក្មេងប្រុស។ អត្រានៃការបោះបង់ការសិក្សារបស់សិស្សទាំងពីរភេទមានចំនួនច្រើនបំផុតនៅថ្នាក់ទី៥ ក៏ប៉ុន្តែជាទូទៅសិស្សប្រុសងាយបោះបង់ចោលសាលាជាងសិស្សស្រី។

[3] ក្រសួងអប់រំ យុវជន និងកីឡា ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ ឆ្នាំ (២០០៨, ២០១២)




*ប្រភព៖ EMIS ក្រសួងអប់រំ យុវជន និងកីឡា*




*ប្រភព៖ EMIS ក្រសួងអប់រំ យុវជន និងកីឡា*




## កុមារីមានឱកាសល្អប្រសើរជាងមុនក្នុងការបញ្ចប់ការសិក្សានៅបឋមសិក្សានិងមធ្យមសិក្សាបឋមភូមិ

▲ ភាគរយនៃនិស្សិតស្រីសិក្សានៅឧត្តមសិក្សាមានការកើនឡើងឥតឈប់ឈរ

- កុមារីមានឱកាសល្អប្រសើរជាងមុនក្នុងការបញ្ចប់ការសិក្សានៅថ្នាក់បឋមសិក្សា ប៉ុន្តែនៅមានគម្លាតយេនឌ័រនៅឡើយនៅកម្រិតខេត្ត និងរវាងទីប្រជុំជននិងតំបន់ដាច់ស្រយាល។

- នៅក្នុងឆ្នាំ២០១២[4] កុមារីបានចុះឈ្មោះចូលរៀនបានច្រើនជាងកុមារា និងមានចំនួនសរុបច្រើនជាងកុមារានៅកម្រិតមធ្យមសិក្សាបឋមភូមិ ប៉ុន្តែទន្ទឹមនឹងនោះអត្រានៃការបោះបង់ចោលការសិក្សារបស់ក្មេងស្រីជាទូទៅនៅតែមានកម្រិតខ្ពស់ជាងក្មេងប្រុស។

- នៅទីប្រជុំជន ក្មេងប្រុសបញ្ចប់ការសិក្សាបានច្រើនជាងក្មេងស្រីនៅកម្រិតមធ្យមសិក្សាបឋមភូមិ។ ជាទូទៅកុមារនៅទីជនបទទទួលការ

[4] ក្រសួងអប់រំ យុវជន និងកីឡា ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ ឆ្នាំ (២០១២)

អប់រំតិចជាងកុមារនៅទីប្រជុំជន។

- ការបន្តការសិក្សារបស់ក្មេងស្រីនៅក្រោយកម្រិតមធ្យមសិក្សាបឋមភូមិនៅមានកម្រិត ហើយក្មេងស្រីមានបញ្ហាប្រឈមច្រើនក្នុងការបញ្ចប់ការសិក្សា។




*ប្រភព៖ EMIS ក្រសួងអប់រំ យុវជន និងកីឡា*

## ការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ មានការរីកចម្រើនគួរឱ្យកត់សម្គាល់ ប៉ុន្តែស្ត្រីនិងក្មេងស្រីត្រូវបានគេរើសអើងលើឱកាសការងារ និងមានប្រាក់ឈ្នួលទាបជាងបុរស និងក្មេងប្រុស

- ស្ត្រីច្រើនទទួលបានតំណែងទាបក្នុងការងារ ហើយការងារភាគច្រើនរបស់ស្ត្រីជាការងារដែលពុំសូវទាមទារជំនាញខ្ពស់ មានតែស្ត្រីមួយចំនួនតូចប៉ុណ្ណោះដែលមានតួនាទីជាអ្នកគ្រប់គ្រង។

- ការងាររបស់ស្ត្រីច្រើនផ្តុំគ្នានៅក្នុងវិស័យមួយចំនួនតូចប៉ុណ្ណោះ ជាពិសេសក្នុងការងារដែលសង្គមពុំសូវឱ្យតម្លៃដូចជាការងារក្នុងសេវាកំសាន្ត ផ្សព្វផ្សាយស្រាបៀរជាដើម។

- ការចូលរួមរបស់ស្ត្រីនៅមានកម្រិតទាបនៅឡើយនៅក្នុងការបណ្តុះបណ្តាលផ្លូវការដែលមានរយៈពេលវែង ជាពិសេសក្នុងជំនាញដែលទីផ្សារត្រូវការនិងមានប្រាក់ឈ្នួលខ្ពស់ ដូចជាក្នុងផ្នែកសំណង់និងមេកានិកជាដើម។
- ទោះបីការចូលរួមរបស់ស្ត្រីនៅក្នុងការអប់រំនិងបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈមានការកើនឡើងក៏ដោយ ក៏ប៉ុន្តែជំនាញដែលផ្តល់ជូនដល់ស្ត្រីភាគច្រើនជាជំនាញតាមបែបប្រពៃណី ដូចជាជំនាញតម្បាញ កាត់ដេរ ធ្វើសក់ សំអាងការនិងការងារសិប្បកម្ម ជាដើម។
- អ្នកបណ្តុះបណ្តាលជាស្ត្រីក៏នៅមានចំនួនតិចតួចផងដែរ នៅតាមបណ្តាស្ថាប័នបណ្តុះបណ្តាលគ្រូបច្ចេកទេស (NTTI)។




*ប្រភពៈដកស្រង់ពីការអង្កេតជាមូលដ្ឋាននៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ*

# បញ្ហាប្រឈម

## កត្តាក្រៅប្រព័ន្ធអប់រំ៖ បញ្ហាប្រឈមផ្នែកសង្គម វប្បធម៌ និងសេដ្ឋកិច្ច

- បទដ្ឋានសង្គមលើទំនាក់ទំនងយេនឌ័រនៅតែជាបញ្ហាប្រឈមដ៏ចម្បងដែលរារាំងដល់ការបង្កើនឱកាសដល់ស្ត្រីនិងក្មេងស្រីក្នុងការទទួលបាននូវការអប់រំនិងការបណ្តុះបណ្តាលនានា។
- បញ្ហាសំខាន់ដែលនៅតែបន្តកើតមាននិងជាឧបសគ្គរារាំងដល់ការសិក្សារបស់កុមារ ជាពិសេសក្មេងស្រី គឺច្រើនកើតមាននៅក្នុងគ្រួសារដែលឪពុកម្តាយជាអនក្ខរជន ឬជាអ្នកដែលទទួលបានការអប់រំទាបដែលភាគច្រើនកើតមាននៅតាមតំបន់ដាច់ស្រយាល។
- ទោះបីជាច្បាប់បានកំណត់អាយុស្របច្បាប់( ១៨ឆ្នាំ )ទាំងពីរភេទសម្រាប់អាពាហ៍ពិពាហ៍ក៏ពិតមែន ប៉ុន្តែការរៀបអាពាហ៍ពិពាហ៍មុនអាយុនេះនៅតែបន្តកើតមាន។
- អំពើហិង្សាក្នុងគ្រួសារបានជះឥទ្ធិពលយ៉ាងខ្លាំងដល់ការសិក្សារបស់កូនចៅ។
- ការបោះបង់ការសិក្សាដើម្បីស្វែងរកប្រាក់ចំណូលសម្រាប់ទ្រទ្រង់ជីវភាពគ្រួសារនៅតែជាអាទិភាពដ៏ខ្ពស់សម្រាប់គ្រួសារក្រីក្រ។
- កុមារដែលជាកូនរបស់ស្ត្រីរងគ្រោះដោយសារអំពើហិង្សាដែលទាក់ទងនឹងយេនឌ័រ ក្មេងស្រីពិការ ស្ត្រីស្រឡាញ់ភេទដូចគ្នា និងអ្នកកែភេទ មានអត្រាអវត្តមាន និងបោះបង់ការសិក្សាខ្ពស់ ដោយសារស្ថានភាពផ្ទាល់ខ្លួន និងស្ថានភាពគ្រួសារ និងការរើសអើងពីមិត្តរួមថ្នាក់។

## បញ្ហានៅកម្រិតសាលា៖

- កិច្ចការពារកុមារនៅមានកម្រិត ជាពិសេសសម្រាប់កុមារី ទាក់ទងនឹងការធ្វើដំណើរទៅមកដោយសុវត្ថិភាព អំពើហិង្សានានានៅក្នុងសាលា និងសុខភាពអនាម័យ។
- គុណភាពនៃការបង្រៀនរបស់គ្រូនិងការរៀនរបស់សិស្សនៅមានកម្រិតនៅឡើយ ទាំងកម្មវិធីសិក្សានិងសៀវភៅសិក្សាជាដើម។

- ក្រុមគ្រួសារនៅតំបន់ជនបទជាពិសេសជនជាតិដើមភាគតិចភាគច្រើន មិនទាន់យល់ដឹងច្បាស់លាស់អំពីអត្ថប្រយោជន៍និងតម្លៃនៃការសិក្សាសម្រាប់អនាគតរបស់កូនចៅ ជាពិសេសសម្រាប់កូនស្រី។
- ផលប៉ះពាល់រយៈពេលវែងនៃកម្មវិធីផ្តល់អាហារូបករណ៍ដល់សិស្សនៅពុំទាន់មានភាពច្បាស់លាស់ថាតើកម្មវិធីនេះបានជួយដល់ក្មេងស្រី និង ក្មេងប្រុសឱ្យបន្តការសិក្សាក្នុងកម្រិតណា។
- កាលវិភាគរបស់សាលាពុំទាន់ឆ្លើយតបពេញលេញទៅតាមតម្រូវការ និងរដូវកាលនៃការធ្វើស្រែចម្ការរបស់ប្រជាជននៅតាមមូលដ្ឋាននៅឡើយ។
- ការចូលរួមរបស់សហគមន៍និងមាតាបិតាសិស្សក្នុងសកម្មភាពរបស់សាលាក៏ដូចជាការសិក្សារបស់សិស្សនៅមានកម្រិត។

## បញ្ហាទាក់ទងនឹងគោលនយោបាយតាមវិស័យនិងសមត្ថភាពស្ថាប័ន

- គោលនយោបាយនិងផែនការត្រូវបានបង្កើតឡើងយ៉ាងល្អ ប៉ុន្តែការអនុវត្តន៍នៅមានកម្រិតនៅឡើយនៅគ្រប់កម្រិតសិក្សា។
- សមត្ថភាពធនធានមនុស្សនិងសមត្ថភាពស្ថាប័នក្នុងការអនុវត្តន៍ការបញ្ជ្រាបយេនឌ័រនៅថ្នាក់ក្រោមជាតិនៅមានភាពទន់ខ្សោយនៅឡើយ។
- សេវាអប់រំមូលដ្ឋានត្រូវបានផ្តល់ដោយឥតគិតថ្លៃ ប៉ុន្តែការចំណាយក្រៅផ្លូវការផ្សេងៗសម្រាប់ការសិក្សារបស់កុមារនៅតែជាកង្វល់របស់មាតាបិតា។

## ក្តីកង្វល់ថ្មីៗ

- កំណើនយ៉ាងឆាប់រហ័សនៃឧស្សាហកម្មនិងសមាហរណកម្មសេដ្ឋកិច្ចអាស៊ានដែលនឹងចាប់ផ្តើមនៅឆ្នាំ២០១៥ រួមជាមួយការកើនឡើងនូវ សម្ពារៈនិយមក្នុងសង្គមនឹងទាមទារនូវកម្មករជំនាញ ព្រមទាំងស្រូបយកក្មេងស្រី ឬក្មេងប្រុសចូលក្នុងទីផ្សារការងារ ។
- ពិការភាពនៅតែជាកត្តាដែលត្រូវបានគេមើលរំលង។

# អនុសាសន៍សម្រាប់គោលនយោបាយ

| ១. ធ្វើការពិនិត្យឡើងវិញនិងកែទម្រង់ក្របខ័ណ្ឌច្បាប់និងគោលនយោបាយនានាក្នុងវិស័យអប់រំដើម្បីពន្លឿនកិច្ចខិតខំប្រឹងប្រែង និងជម្រុញការបញ្ជ្រាបយេនឌ័រទៅក្នុង និងតាមរយៈវិស័យអប់រំ | |
|---|---|
| • គួរផ្តល់អាទិភាពក្នុងការដាក់បញ្ចូលការអប់រំមូលដ្ឋានរយៈពេល៩ឆ្នាំជាកាតព្វកិច្ចនៅក្នុងច្បាប់និងអនុម័តយន្តការរដ្ឋបាលនិងវិធានការចាំបាច់ នានា។ | សភាជាតិ<br>ក្រសួងអប់រំ យុវជន និងកីឡា<br>ក្រសួងព័ត៌មាន<br>ស្ថាប័នពាក់ព័ន្ធ |
| • គួរមានយន្តការពិសេស និងបន្ទាន់សម្រាប់ស្ត្រីនិងកុមារជនជាតិដើមភាគតិចដើម្បីធានានូវការទទួលបានគុណភាពនិងបរិមាណសម្រាប់ការអប់រំមូលដ្ឋានរយៈពេល៩ឆ្នាំ។ | ក្រសួងអប់រំ យុវជន និងកីឡា<br>ស្ថាប័នពាក់ព័ន្ធ |
| • បញ្ចូលមាត្រា១ មាត្រា១០ និង១៣ នៃអនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រី (CEDAW)ទៅក្នុងកម្មវិធីសិក្សា របស់សាលាបឋមសិក្សាចាប់ពីថ្នាក់ទី៦ឡើងទៅ និងបណ្តុះបណ្តាល គ្រូបង្រៀនអំពី ខ្លឹមសារនៃអនុសញ្ញានេះ។ | ក្រសួងអប់រំ យុវជន និងកីឡា<br>ស្ថាប័នពាក់ព័ន្ធ |
| • ពង្រឹងការអនុវត្តផែនការសកម្មភាពបញ្ជ្រាបយេនឌ័រនៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈនិងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ។ | ក្រសួងអប់រំ យុវជន និងកីឡា<br>ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក.ក.ន<br>ក្រសួងពាក់ព័ន្ធ |

| | |
|---|---|
| • ត្រៀមថវិកានិងធនធានសម្ភារៈឱ្យបានគ្រប់គ្រាន់ដើម្បីលុបបំបាត់រាល់ការចំណាយក្រៅផ្លូវការនិងការចំណាយផ្ទាល់ (direct costs) ក្នុងការទទួលបានការសិក្សារបស់សិស្ស។ | ក្រសួងអប់រំ យុវជន និងកីឡា<br>ក្រសួងពាក់ព័ន្ធ |
| • ពង្រឹងភាពស៊ីសង្វាក់គ្នារវាងគោលនយោបាយនិងផែនការសម្រាប់ការអប់រំនិងការបណ្តុះបណ្តាលវិជ្ជាជីវៈ ជាមួយនឹងផែនការយុទ្ធសាស្ត្រនិង គោលនយោបាយបញ្ជ្រាបយេនឌ័រក្នុងវិស័យរបស់ខ្លួន និងជាមួយវិស័យផ្សេងៗទៀត។ | ក្រសួងអប់រំ យុវជន និងកីឡា<br>ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងពាក់ព័ន្ធ |

## ២. ពង្រឹងសមត្ថភាពធនធានមនុស្សនិងស្ថាប័នដើម្បីអនុវត្ត និងពិនិត្យតាមដាននូវការអនុវត្តន៍គោលនយោបាយ និងផែនការនានា សម្រាប់ការបញ្ជ្រាបយេនឌ័រ

| | |
|---|---|
| • ពង្រីកទំហំការងាររបស់ក្រុមការងារយេនឌ័រ ឬ គណៈកម្មាធិការយេនឌ័រ នៃក្រសួងអប់រំយុវជននិងកីឡា និងក្រសួងពាក់ព័ន្ធក្នុងការគាំទ្រដល់ថ្នាក់ក្រោមជាតិ ដើម្បីអនុវត្តអនុសញ្ញាCEDAW និងការបញ្ជ្រាបយេនឌ័រ។ | ក្រសួងអប់រំ យុវជន និង កីឡា<br>ក្រសួងពាក់ព័ន្ធ |
| • បន្តនិងជំរុញការរៀបចំកម្មវិធីបណ្តុះបណ្តាលស្តីពីអនុសញ្ញាCEDAW និងយេនឌ័រឱ្យបានទៀងទាត់នៅថ្នាក់ក្រោមជាតិ ដោយសហការជាមួយក្រសួងកិច្ចការនារី។ | ក្រសួងអប់រំ យុវជន និង កីឡា<br>ក.ក.ន.<br>គ.ជ.ស.ស.ខ. |
| • ពន្លឿនការអនុវត្តន៍សកម្មភាពវិជ្ជមាន (Affirmative Action) នៃអនុសញ្ញា CEDAW មាត្រា៤ ដើម្បីបង្កើនចំនួនបុគ្គលិកជាស្ត្រីនៅគ្រប់កម្រិតរាប់បញ្ចូលទាំងថ្នាក់ដឹកនាំរដ្ឋបាលក៏ដូចជាថ្នាក់ដឹកនាំតាមសាលានិងគ្រឹះស្ថានសិក្សា។ | ក្រសួងអប់រំ យុវជន និង កីឡា<br>ក្រសួងពាក់ព័ន្ធ |

| | |
|---|---|
| • ពន្លឿនការពង្រីកកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនដោយផ្តល់អាទិភាព លើការបង្កើនបរិមាណគ្រូបង្រៀនជាស្ត្រីឱ្យបានច្រើននៅកម្រិតមធ្យមសិក្សានិងក្នុងផ្នែកបណ្តុះបណ្តាលវិជ្ជាជីវៈ។ | ក្រសួងអប់រំ យុវជន និង កីឡា<br>ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>ក្រសួងពាក់ព័ន្ធ |

៣.ពង្រឹងការរៀបចំកម្មវិធីដាក់លាក់ផ្នែកយេនឌ័រនិងកែលម្អគុណភាពនៃការអប់រំនិងការបណ្តុះបណ្តាលសម្រាប់ស្ត្រីនិង ក្មេងស្រី ជាពិសេសផ្តល់ការយកចិត្តទុកដាក់ដល់ស្ត្រី និងក្មេងស្រីជនជាតិដើមភាគតិច និងពិការ។

| | |
|---|---|
| • ពង្រីកលទ្ធភាពនៃការទទួលបាននូវការអប់រំស្មើគ្នាជាពិសេសកម្រិតមធ្យមសិក្សា និងក្នុងផ្នែកបណ្តុះបណ្តាលវិជ្ជាជីវៈ។ | ក.ក.ន.ក្រសួងអប់រំ យុវជន និងកីឡា<br>ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>ក្រសួងពាក់ព័ន្ធ |
| • ប្រែក្លាយការផ្តល់ប្រឹក្សាយោបល់ដែលឆ្លើយតបនឹងយេនឌ័រឱ្យមានលក្ខណៈជាប្រព័ន្ធ ដើម្បីផ្តល់ការណែនាំសម្រាប់ទិសដៅអនាគតឱ្យសមស្របតាមពេលវេលានិងអាយុរបស់ក្មេងប្រុស និងក្មេងស្រី តាមរយៈការបណ្តុះបណ្តាលលើជំនាញនេះដល់គ្រូបង្រៀន។ ពង្រីកនិងពង្រឹងកម្មវិធីផ្តល់ប្រឹក្សាដល់ក្មេងស្រីដែលមានស្រាប់ និងប្រព័ន្ធតាមដាន ។ | ក.ក.ន.<br>ក្រសួងអប់រំយុវជន និងកីឡា<br>ក្រសួងពាក់ព័ន្ធ |

| | |
|---|---|
| • ធ្វើពិពិធកម្មក្នុងការផ្តល់ការអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈនៅកម្រិតមធ្យមសិក្សានិងក្នុងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់ស្ត្រីនិងក្មេងស្រី។ | ក្រសួងអប់រំយុវជន និងកីឡា<br>ក.ក.ន.<br>ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈក្រសួងពាក់ព័ន្ធ |
| • ពង្រឹងនិងពង្រីកកម្មវិធីអក្ខរកម្មនិងកម្មវិធីអប់រំក្រៅប្រព័ន្ធសម្រាប់ស្ត្រីនិងក្មេងស្រីវ័យជំទង់ដែលនៅក្រៅសាលារៀនដើម្បីលើកកម្ពស់ភាពអង់អាចរបស់ពួកគេតាមរយៈការបណ្តុះបណ្តាលជំនាញ។ | ក្រសួងអប់រំយុវជន និងកីឡា<br>ក.ក.ន. រដ្ឋបាលថ្នាក់ក្រោមជាតិ<br>ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងពាក់ព័ន្ធ |
| • ពង្រឹង និងពង្រីកកម្មវិធីគាំពារនិងការអប់រំកុមារតូចនិងបង្កើនការចូលរៀនរបស់កុមារតូច ឱ្យបានយ៉ាងហោចណាស់១ឆ្នាំមុនចូលរៀនថ្នាក់បឋមសិក្សា។ | ក្រសួងអប់រំយុវជន និងកីឡា<br>ក.ក.ន.<br>រដ្ឋបាលថ្នាក់ក្រោមជាតិ |
| • លើកកម្ពស់កម្មវិធីប្រឹក្សាអាជីពដើម្បីឱ្យស្ត្រីបានយល់ដឹងអំពីឱកាសការងារ និងការធ្វើជំនួញ។ | ក.ក.ន.<br>ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈក្រសួងពាក់ព័ន្ធ |

## ៤.បង្កើនកិច្ចខិតខំប្រឹងប្រែងក្នុងការស្វែងរកការគាំទ្រមតិនិងការលើកកម្ពស់ការយល់ដឹង ដើម្បីលុបបំបាត់ផ្នត់គំនិតសង្គមដែលរើសអើងលើស្ត្រី និងក្មេងស្រី

| | |
|---|---|
| • ធ្វើឱ្យប្រសើរឡើងនូវកិច្ចសហប្រតិបត្តិការរវាងក្រសួងអប់រំ យុវជននិងកីឡា ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងកិច្ចការនារី និងបណ្តាក្រសួងពាក់ព័ន្ធលើការស្វែងរកការគាំទ្រមតិ និងការបង្កើនការយល់ដឹងទាក់ទងនឹងយេនឌ័រក្នុងការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ | ក.ក.ន<br>ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងអប់រំ យុវជន និងកីឡា<br>ក្រសួងពាក់ព័ន្ធ |
| • ពង្រឹងគណៈកម្មាការទ្រទ្រង់សាលារៀន និងយន្តការមូលដ្ឋានក្នុងការជំរុញឱ្យមាតាបិតានិងសហគមន៍ចូលរួមសហការក្នុងការគាំទ្រសាលារៀននិងគ្រូបង្រៀនពាក់ព័ន្ធនឹងការលើកកម្ពស់សមភាពយេនឌ័រនៅក្នុងសកម្មភាពបង្រៀនក៏ដូចជាការរៀនសូត្រប្រចាំថ្ងៃ។ | ក.ក.ន<br>ក្រសួងអប់រំ យុវជន និងកីឡា<br>រដ្ឋបាលថ្នាក់ក្រោមជាតិ<br>ក្រសួងពាក់ព័ន្ធ |
| • ពង្រឹងកិច្ចសហការឱ្យកាន់តែជិតស្និទ្ធរវាងក្រសួងពាក់ព័ន្ធជាមួយនឹងប្រព័ន្ធផ្សព្វផ្សាយដើម្បីលើកកម្ពស់ការផ្លាស់ប្តូរផ្នត់គំនិតដែលពាក់ព័ន្ធនឹងយេនឌ័រ ជាពិសេសពាក់ព័ន្ធការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ | ក្រសួងអប់រំយុវជន និងកីឡា<br>ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>ក.ក.ន<br>ក្រសួងព័ត៌មាន<br>គ.ជ.ស.ស.ខ.<br>ក្រសួងពាក់ព័ន្ធ |
| • រៀបចំស្រាវជ្រាវបន្ថែមទៀតដើម្បីបង្កើនទិន្នន័យលើបញ្ហាយេនឌ័រក្នុងការអប់រំ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងទីផ្សារការងារ។ | ក.ក.ន<br>ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>ក្រសួងអប់រំយុវជន និងកីឡា<br>ក្រសួងពាក់ព័ន្ធ |

# សេចក្តីថ្លែងអំណរគុណ

ការប៉ាន់ប្រមាណយេនឌ័រនៅកម្ពុជាត្រូវបានចងក្រងឡើងនៅក្រោមការដឹកនាំ និងសម្របសម្រួលដោយក្រសួងកិច្ចការនារី ដោយមានការគាំទ្រនិងរួមចំណែកពីក្រសួងស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល។ ក្រសួងកិច្ចការនារីសូមថ្លែងអំណរគុណជូនចំពោះលោកជំទាវ ឯកឧត្តម លោក លោកស្រី ដែលបានចូលរួមចំណែកក្នុងការរៀបចំឯកសារនេះ ដូចតទៅ៖

**ក្រុមការងាររៀបចំការប៉ាន់ប្រមាណយេនឌ័រនៅកម្ពុជា** ទទួលខុសត្រូវលើដំណើរការរៀប ចំឯកសារទាំងមូល ក្រោមការដឹកនាំរបស់ លោកជំទាវ វេជ្ជបណ្ឌិត អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ។ ក្រុមការងារមានលោកជំទាវ ឃឹម ចំរើន រដ្ឋលេខាធិការជាប្រធាន និងគាំទ្របច្ចេកទេសដោយផ្ទាល់ពីលោកជំទាវ កេត សំអាត ទីប្រឹក្សាជាន់ខ្ពស់ក្រសួងកិច្ចការនារី លោកជំទាវ គឹម ស៊ីផាត់ អគ្គនាយិកា ក្រសួងកិច្ចការនារី និង លោក ថៃ ឈុនហាក់អគ្គនាយករងក្រសួងកិច្ចការនារីលោកស្រី ញាណ សុចិត្រា ប្រធាននាយកដ្ឋានសមភាពយេនឌ័រ លោកស្រី តែ វួចលីម ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ និងសមាជិកផ្សេងៗទៀតមកពីនាយកដ្ឋានបច្ចេកទេសនានាចំណុះក្រសួងកិច្ចការនារី។ ក្រុមការងារមានការគាំទ្រផ្នែកបច្ចេកទេសពីគម្រោង **ភាពជាដៃគូដើម្បីសមធម៌យេនឌ័រ** (PGEIII) ដែលមានលោកស្រី Mia Hyun ជាទីប្រឹក្សាជាន់ខ្ពស់ប្រចាំក្រសួងកិច្ចការនារី ជាអ្នកសម្របសម្រួលទូទៅ គាំទ្រដោយក្រុមអ្នកជំនាញតាមវិស័យរបស់គម្រោង រួមមាន លោកស្រី ឌី ម៉ានី លោក ប៉ែន បូរី លោកស្រី ហេង សិលទិ លោក ឈន ថាវរិទ្ធិ និង លោក គឹម សុពណ៌។ **ក្រុមការងារបច្ចេកទេសយេនឌ័រ** (TWG-G) បានផ្តល់ជាវេទិកាដ៏សំខាន់ក្នុងការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងក្រុមអ្នកជួយកែសម្រួល (peer reviewers) ដែលជាអ្នកជំនាញមកពីក្រសួងកិច្ចការនារី ក្រសួងពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល បានជួយពិនិត្យ ឡើងវិញលើសេចក្តីព្រាងតាមជំនាញពាក់ព័ន្ធ។ បច្ចេកទេសទាក់ទងនឹងរូបភាពការរចនា និងសម្ភារៈសម្រាប់ផ្សព្វផ្សាយផ្តល់ដោយ Good Morning Beautiful ។

ក្រុមអ្នកដឹកនាំនិងរៀបចំជំពូកទី៤៖ ជំពូកនេះដឹកនាំរៀបចំដោយលោកជំទាវ ខេង សំវ៉ាដា និងលោកជំទាវ អ៊ឹម ស៊ីថៃ និងសរសេរសេចក្តីព្រាងដោយលោកស្រី Maki Hayashikawa (UNESCO Paris) និងលោក Santosh Khatri (UNESCO Phnom

Penh) ឧបត្ថម្ភដោយ UNICEF និង UNESCO ដោយមានការផ្តល់ធាតុចូលពី ឯកឧត្តម ណាត ប៊ុនរឿន រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា លោកស្រី ឡុង និមល អគ្គនាយិកាក្រសួងកិច្ចការនារី លោកស្រី នុំ បូផារី ប្រធាននាយកដ្ឋានស្ត្រីនិងការអប់រំនៃក្រសួងកិច្ចការនារី លោក តឹប អឿន មន្ត្រីជំនាញមកពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លោកស្រី Erika Boak (UNICEF) លោកស្រី Lisa Kim (UNICEF) លោកស្រី Naomi Neijhoft (UNICEF) លោក សុទ្ធ និមល (UNESCO) និង លោកស្រី ឯក សុផាណា (Plan International)។

ក្រសួងកិច្ចការនារី
ផ្លូវទ្រុងមាន់ ភូមិដំណាក់ធំ ៣ សង្កាត់ស្ទឹងមានជ័យ
ក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ហ្វាក់ : (+៨៥៥) ២៣ ៨៨០ ៧៣៧
អ៊ីម៉ែល : mwa@online.com.kh
វេបសាយ : www.mowa.gov.kh
ហ្វេសប៊ុក : www.facebook.com/mowa.gov.kh